ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សារលិខិតរំលែកទុក្ខ

**ជូនចំពោះ**
**លោកស្រី ឆែម កល្យាណ និងលោកស្រី ខាន់ ចាន់ថុល ព្រមទាំងក្រុមគ្រួសារ**

*លោកស្រី ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អាន!*

ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីរន្ធត់ចិត្តក្តុកក្តួលយ៉ាងក្រៃលែង នៃមរណភាពរបស់ លោកអនុសេនីយ៍ឯក **ខេង ឆៃយុទ្ធ** និង លោកវរសេនីយ៍ទោ **ស៊ុន ផល្លា** យោធិនអាកាសយានិកនៃកងយុទ្ធពលខេមរភូមិន្ទ ដែលជាស្វាមីរបស់លោកស្រី ក្នុងឧបទ្ទវហេតុធ្លាក់ឧទ្ធម្ភាគចក្រ កាលពីថ្ងៃសុក្រ ទី១២ ខែកក្កដា ឆ្នាំ២០២៤ នៅក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់កន្លងមកនេះ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវសេចក្តីសោកស្តាយជាទីបំផុត ចំពោះលោកស្រីទាំងពីររូបព្រមទាំងក្រុមគ្រួសារ ដែលនេះជាការបាត់បង់នូវស្វាមីប្រកបដោយសង្គហធម៌ ឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះបុត្រធីតា និងជាអាកាសយានិកដ៏អង់អាចក្លាហាន ដែលបានចូលរួមធ្វើពលិកម្មគ្រប់បែបយ៉ាងប្រកបដោយឆន្ទៈមនសិការដ៏មោះមុត ក្នុងបុព្វហេតុបម្រើជាតិ សាសនា ព្រះមហាក្សត្រ និងការពារបូរណភាពទឹកដីជារៀងរហូតមក។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធរបស់ **លោកអនុសេនីយ៍ឯក ខេង ឆៃយុទ្ធ** និងលោកវរសេនីយ៍ទោ **ស៊ុន ផល្លា** សូមបានទៅសោយសុខក្នុងឋានសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកស្រី ឆែម កល្យាណ និងលោកស្រី ខាន់ ចាន់ថុល ព្រមទាំងក្រុមគ្រួសារ ទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំនេះ និងការស្រលាញ់រាប់អានយ៉ាងជ្រាលជ្រៅពីយើងខ្ញុំ។

ថ្ងៃអង្គារ ១០រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៤
**រដ្ឋមន្ត្រី**

**ហេង សួរ**